# ទិដ្ឋាការចេញចូលមួយដង គោលបំណងទេសចរណ៍

ទិដ្ឋាការប្រភេទនេះគឺសម្រាប់**គោលបំណងទេសចរណ៍តែមួយគត់** ដោយសាមីជន**ត្រូវស្នាក់នៅសណ្ឋាគារ**អំឡុងពេលដំណើរកម្សាន្តនៅប្រទេសជប៉ុន។ ក្នុងករណីគោលបំណងក្រៅពីទេសចរណ៍ (ទៅលេង/ស្នាក់នៅផ្ទះរបស់មិត្តភក្តិ ឬសាច់ញាតិ) សូមស្នើសុំទិដ្ឋាការទៅលេងមិត្តភក្តិ ឬទៅលេងសាច់ញាតិ។ ស្ថានទូតនឹងមិនទទួលរាល់ពាក្យស្នើសុំទិដ្ឋាការណាដែលមិនបំពេញតាមលក្ខខណ្ឌ ដូច្នេះសូមរៀបចំនិងពិនិត្យឯកសារឲ្យបានត្រឹមត្រូវមុនពេលមកដាក់ពាក្យ។

| | | ឯកសារតម្រូវ | កំណត់ចំណាំ |
|---|---|---|---|
| ១ | ☐ | លិខិតឆ្លងដែន **ច្បាប់ដើម** | · មិនមានស្នាមប្រឡាក់ ឬការខូចខាត<br>· ត្រូវមាន២ទំព័រសម្រាប់បិទទិដ្ឋាការ |
| ២ | ☐ | ពាក្យស្នើសុំទិដ្ឋាការ ***ច្បាប់ដើម***<br>*(បិទរូបថត១សន្លឹក)*<br><br>សេចក្ដីពន្យល់អំពីការបំពេញពាក្យស្នើសុំ (ខ្មែរ) | · រូបថតបិទកាត (ថតថ្មីក្នុងរយៈពេល៦ខែ)<br>(បណ្ដោយ: ៤.៥សង់ទីម៉ែត្រ x ទទឹង: ៣.៥សង់ទីម៉ែត្រ, ផ្ទៃពណ៌ស, រូបថតពណ៌ ឬសខ្មៅ)<br>· បំពេញពាក្យ"N/A"សម្រាប់សំណួរដែលមិនត្រូវនឹងលក្ខខណ្ឌរបស់អ្នក |
| ៣ | ☐ | តារាងស្នាក់នៅ | - សរសេរលម្អិតពីសកម្មភាពប្រចាំថ្ងៃ(ចាប់ពីថ្ងៃចូលរហូតដល់ចេញពីប្រទេសជប៉ុន)<br>- គម្រោងថ្ងៃចូលនិង ចេញពីជប៉ុន, ជើងហោះហើរដែលអ្នកគ្រោងជិះ, ឈ្មោះព្រលានសម្រាប់ហោះចូល និងចេញពីប្រទេសជប៉ុន<br>- បំពេញពត៌មានកន្លែងស្នាក់/សណ្ឋាគារ (ឈ្មោះ, អាស័យដ្ឋាន, លេខទូរស័ព្ទ) |
| ៤ | ☐ | ឯកសារកក់សណ្ឋាគារ | · មានឈ្មោះរបស់សាមីជន និងថ្ងៃស្នាក់នៅ |
| ៥ | ☐ | ឯកសារបញ្ជាក់លទ្ធភាពរ៉ាប់រងលើការចំណាយ | · សេចក្ដីចម្លងតុល្យបញ្ជីគណនី Bank statements (ធ្វើបច្ចុប្បន្នភាពកំឡុងពេល៣ខែចុងក្រោយមកទល់នឹងថ្ងៃដាក់ពាក្យស្នើទិដ្ឋាការ)<br>មិនមែន BANK CONFIRMATION.<br>· ករណីមានអ្នកធានាលើការចំណាយ<br>ក. ឯកសារបញ្ជាក់ទំនាក់ទំនងរវាងអ្នកសាមីជន និង អ្នកធានា (សៀវភៅគ្រួសារជាដើម) |

| | | | |
|---|---|---|---|
| | | | ខ. លិខិតធានា (មានសរសេរបញ្ជាក់ទំនាក់ទំនងជាដើម ,គំរូ)<br>គ. សេចក្តីចម្លងតុល្យបញ្ជីគណនី Bank statements របស់អ្នកធានា |
| ៦ | □ | លិខិតអនុញ្ញាតក្នុងការធ្វើដំណើរ | · ករណីអនីតិជនធ្វើដំណើរដោយគ្មានឪពុកម្តាយអមជាមួយ (មិនមានកំណត់ទម្រង់សរសេរ)<br>· ឯកសារបង្ហាញពីទំនាក់ទំនងឪពុកម្តាយ (សៀវភៅគ្រួសារ, សំបុត្រកំណើត។ល។) |